ក្រសួងសុខាភិបាល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ 936.....អបស/ក្រឱសស

រាជធានីភ្នំពេញ ថ្ងៃទី20 ខែ12 ឆ្នាំ២០០០

# សេចក្តីសំរេច

ស្តីពី

## ការអនុញ្ញាតអោយដឹកផលិតផលឱសថតាមរថយន្តទៅចែកចាយ តាមខេត្តនិងក្រុងនានា ក្នុងព្រះរាជាណាចក្រកម្ពុជា

### ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញ ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧_មិថុនា_១៩៩៦ ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញ អនុក្រឹត្យលេខ ៦៧ អនក្របក ចុះថ្ងៃទី ២២ តុលា ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- បានឃើញ លិខិតលេខ ៦៥៩ អបស/ឱអបស ចុះថ្ងៃទី ០១ កញ្ញា ២០០០ របស់ក្រសួងសុខាភិបាល
- បានឃើញ លិខិតស្នើសុំលេខ 033 មម ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០០ របស់គ្រឹះស្ថានអាហ៊័រណេ ឱហ៊័រណេឱសថ មតាមេឌិខល ។

## សំរេច

ប្រការ១ .- អនុញ្ញាតអោយគ្រឹះស្ថានអាហ៊័រណេ ឱហ៊័រណេឱសថ មតាមេឌិខល ដឹកផលិតផលឱសថតាមរថយន្ត ដើម្បីយកទៅចែកចាយដល់ឱសថស្ថានឱសថស្ថានរងនានា ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា តាមបញ្ជីរាយឈ្មោះផលិតផល។

ប្រការ២ .- គ្រឹះស្ថានអាហ៊័រណេ ឱហ៊័រណេឱសថ មតាមេឌិខល ត្រូវចែកចាយតាមការបញ្ជាទិញរបស់ឱសថស្ថាន ឱសថស្ថានរងដែលមានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល និងត្រូវចែកចាយតែឱសថ ដែលមានលេខទិដ្ឋាការ_បញ្ជិកាពីក្រសួងសុខាភិបាលតែប៉ុណ្ណោះ ។

ប្រការ៣ .- អគ្គាធិការដ្ឋាន_អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង ព្រមទាំងគ្រឹះស្ថានអាហ៊័រណេ ឱហ៊័រណេឱសថ មតាមេឌិខល ត្រូវទទួលភារៈអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅរហូតដល់ពេលផុតកំណត់នៅថ្ងៃទី ០១_១២_២០០១។

ចម្លងជូន :
- គ្រប់សាលាខេត្ត-ក្រុង
- ក្រសួងមហាផ្ទៃ "ដើម្បីសហការ"
- គ្រប់មន្ទីរសុខាភិបាលខេត្ត-ក្រុង "ដើម្បីតាមដានការអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

ជ.ទេសរដ្ឋមន្ត្រី_រដ្ឋមន្ត្រីក្រសួងសុខាភិបាល
រដ្ឋលេខាធិការ

វេជ្ជ.អ៊ិច_ភីរុន